**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៤.០៧៥/០៩ គ.ជ.ប/អគ្គ.ពស**

រាជធានីភ្នំពេញ ថ្ងៃទី 12 ខែមេសា ឆ្នាំ ២០០៩

# បញ្ជីបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឆ្នាំ២០០៩ ត្រូវបាន គ.ជ.ប ផ្តល់សុពលភាពជាផ្លូវការ

ផ្អែកតាមប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៩ នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតជាផ្លូវការ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលមានអ្នកបោះឆ្នោតសរុបទាំងអស់ ចំនួន **១១៣៥៣ នាក់** នៅទូទាំងប្រទេស ។

យោងតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ បញ្ជីបោះឆ្នោតដែលត្រូវផ្តល់សុពលភាពជាផ្លូវការរួចហើយមិនអាចកែប្រែបានឡើយ លើកលែងតែមានអ្នកបោះឆ្នោតណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះទទួលមរណភាព ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា គ.ជ.ប បានណែនាំទៅគ្រប់គណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត (គធ/ខប) ទាំង ២៤ ឱ្យបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការក្នុងរយៈពេលយ៉ាងតិច ៣០ថ្ងៃ មុនថ្ងៃបោះឆ្នោត នៅការិយាល័យបោះឆ្នោត និងនៅទីកន្លែងសាធារណៈណាមួយក្នុងមណ្ឌលបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សា ។ ឯកឧត្តមបានបន្តថា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានេះមានការិយាល័យបោះឆ្នោត ចំនួន **១៩៣ ការិយាល័យ** ហើយថ្ងៃបោះឆ្នោត គឺនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៩ ខាងមុខនេះ ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងទូរស័ព្ទលេខ: ០២៣ ២១៤ ៣៧៤ / ០១២ ៨៥៥ ០១៨ E-mail: necinfo@forum.org.kh ; Website: www.necelect.org.kh